# មជ្ឈមណ្ឌលកុំព្យូទ័រ
## និងជំនាញបច្ចេកវិទ្យា សុវណ្ណរក្ស

SovanReak Computer Center & Technology Skills

# មេរៀន
# និងលំហាត់ PHOTOSHOP
## វគ្គដំបូង

សម្រាប់អ្នកមិនទាន់ចេះសោះ

រៀបរៀង និងបង្រៀនដោយ៖

**លោកគ្រូ នន់ សុវណ្ណរាជ**




Adobe Photoshop

# ការណែនាំឱ្យស្គាល់ Abode Photoshop 2021

## ក. និយមន័យ Abode Photoshop

នៅពេលបច្ចុប្បន្នេះការងារដែលទាក់ទងនឹងការរចនាផ្សេងៗ។ កម្មវិធី Abode Photoshop 2021 ហើយជាកម្មវិធីមួយដែលមានប្រជាប្រិយភាពបំផុត ដែលគេនិយមប្រើដើម្បី រចនា រូបភាព ផ្លាកសញ្ញា ផ្លាកយីហោផ្សេងៗ ធ្វើការបង្កើត ឬច្នៃប្រឌិតអ្វីដែលថ្មីមួយចំនួន ផងដែរនៅក្នុងកម្មវិធី Adobe Photoshop 2021 លោកអ្នកអាចមានសមត្ថភាពធ្វើបានដូចជា៖

- ❖ លោកអ្នកអាចបង្កើតជាផ្លាកយីហោ ឬ ជាផ្ទាំងបដាផ្សាយពាណិជ្ជកម្មដែលរចនាទាំងរូបភាព និង អក្សរបានយ៉ាងល្អប្រសើរទៀតផង។
- ❖ លោកអ្នកអាចបង្កើតជា Logo បានយ៉ាងល្អប្រសើរសម្រាប់ក្រុមហ៊ុន ស្ថាប័ន សហគ្រាស ឬ ផ្ទាល់ ខ្លួន និងមានការចាប់អារម្មណ៍ពីសំណាក់អ្នកមើលផងដែរ។
- ❖ លោកអ្នកអាចបង្កើតនៅភាពច្នៃប្រឌិតរូបភាពមួយចំនួនទៀតដូចជា: ក្របសៀវភៅ គំរបរបស់

CD, DVD, VCD ជាដើម។ ជំនាន់របស់កម្មវិធី Adobe Photoshop មាន Adobe Photoshop Older version, Adobe Photoshop Cs, Adobe Photoshop CS2, Adobe Photoshop CS3, Adobe Photoshop CS4, Adobe Photoshop CS5, Adobe Photoshop CS6, Adobe Photoshop CC, Adobe Photoshop CC 2014, Adobe Photoshop CC 2015, Adobe Photoshop CC 2017, Adobe Photoshop CC 2018, Adobe Photoshop CC 2019, Adobe Photoshop CC 2020, Adobe Photoshop CC 2021, Adobe Photoshop 2022, Adobe Photoshop CC 2024……………………

- Adobe Photoshop 2021 ជាកម្មវិធីមួយដែលមានគុណភាពល្អក្នុងការបង្កើតជារូបភាព ផ្សេងៗ តាមតំរូវការរបស់លោកអ្នក។ ហើយលក្ខណៈពិសេសមួយទៀតរូបភាពដែលបានកែច្នៃ បង្កើត របស់ Adobe Photoshop 2021 នេះអាចយកទៅប្រើប្រាស់បន្តជាមួយកម្មវិធីផ្សេងៗ ដូចជា៖ Adobe Illustrator, Adobe Premiere, Adobe InDesign, Webpage

## ខ. របៀបបើកកម្មវិធី Adobe Photoshop 2021

→ ចុចលើ Start Menu + R រួចវាយពាក្យថា Photoshop → Enter រឺចុច (OK)



## គ. ពិពណ៌នាអំពីផ្ទាំងកម្មវិធី

1. ជា Menu Bar: សម្រាប់ចូលទៅប្រើប្រាស់នៅ Option សំខាន់ដែលមិនអាចខ្វះបាន។

2. ជា Option Bar: ដែលសម្រាប់ធ្វើការងារផ្សេងៗចាំបាច់ហើយវាបានបន្ថែមនៅភាពងាយស្រួល ដល់លោកអ្នក និងវាប្រែប្រួលទៅតាមឧបករណ៍ (Tool) ដែលយកមកប្រើ។

3. ជា Option: មួយដែលសម្រាប់បញ្ជាអោយកម្មវិធីបើកផ្ទាំងសន្លឹកកិច្ចការធំ (Maximize) បង្រួម អោយតូច (Minimize) និង ចាកចេញពីកម្មវិធី (Close)។

4. ជា Panel: សម្រាប់កំណត់ការធ្វើការងារផ្សេងៗហើយវាប្រែប្រួលអាស្រ័យទៅតាម Layout និងការងារដែលលោកអ្នកធ្វើលើវា។

5. ជា Panel Tool: ប្រើសម្រាប់យកឧបករណ៍មកប្រើប្រាស់តាមតំរូវការ។

6. Area: ជាផ្ទៃសម្រាប់ធ្វើការងារ។

## ឃ. ដំណោះស្រាយភាពច្បាស់នៃឯកសារ

ដើម្បីធ្វើការកំណត់ឯកសារអោយវាមានទំហំធំ និងច្បាស់ជាងមុនយើងត្រូវធ្វើដូចរូបខាងក្រោម៖

→ ដំបូងយើងត្រូវបើកឯកសាណាមួយសិនដែលមានទំហំតូចល្មម រួចយើងធ្វើការពង្រីកទំហំគុណភាពរបស់វា

- យើងត្រូវ Right Click លើ Title របស់រូបភាព

- បន្ទាប់មក ជ្រើសរើសយកពាក្យថា Image Size

→ Width សម្រាប់កំណត់ប្រវែង ទទឹង

→ Height សម្រាប់កំណត់ប្រវែង កំពស់

→ Resolution សម្រាប់កំណត់ភាពច្បាស់របស់រូបភាព បន្ទាប់មកទៀតយើងធ្វើការវាយតម្លៃលេខនៅត្រង់ប្រអប់ Resolution

— រួចចុច OK រួចជាការស្រេច

ចំណាំ៖ តម្លៃលេខកាន់តែច្រើនគុណភាពរូបកាន់តែច្បាស់ និងស៊ីកាន់តែច្រើនដោយគុណ ភាពរូបភាពភាគច្រើនគេយកត្រឹម 72 ឬ 300 ។

## ខ. ដោះស្រាយនការរឿងពុម្ព

- ដំបូងយើងចុចលើ Menu Image

បន្ទាប់មក ជ្រើសរើសយកពាក្យថា Image Size

→ Width សម្រាប់កំណត់ប្រវែង ទទឹង

→ Height សម្រាប់កំណត់ប្រវែង កំពស់

→ Resolution សម្រាប់កំណត់ភាពច្បាស់របស់រូបភាព

- បន្ទាប់មកទៀតយើងធ្វើការវាយតម្លៃលេខនៅត្រង់ប្រអប់ Resolution

— រួចចុច OK រួចជាការស្រេច

## ច. របៀបបង្កើតសន្លឹកកិច្ចការថ្មី (New Document)

❖ ទម្រង់នៃការបង្កើតសន្លឹកកច្ចការ ដើម្បីបង្កើតសន្លឹកកិច្ចការថ្មីលោកអ្នកចុចដូចខាងក្រោម៖

→ ដំបូងចុចលើពាក្យ File → New ( Ctrl + N )

→ រួចកំណត់ដូចខាងក្រោម

→ ចុច File → New ( Ctrl + N )

→ Name សម្រាប់ដាក់ឈ្មោះ Background

→ Preset សម្រាប់កំណត់យកប្រភេទក្រដាស់ → Size សម្រាប់ជ្រើសរើសយកទម្រង់ក្រដាស់

→ Width សម្រាប់កំណត់ប្រវែង ទទឹង Height សម្រាប់កំណត់ប្រវែង កំពស់

→ Resolution សម្រាប់កំណត់ភាពច្បាស់របស់រូបភាព → Color Mode សម្រាប់ជ្រើសរើសយកប្រភេទពណ៌របស់ Background

→ Background Contents សម្រាប់កំណត់យកប្រភេទ Background

❖ ការផ្លាស់ប្តូរទម្រង់សន្លឹកកច្ចការ ( Changing the workspace ) Workspace គឺជាតំបន់ការងារទាំងមូលនៃកម្មវិធី Photoshop ។ វាជាអ្វីដែល compasses Menu ទាំងអស់នៃឧបករណ៍។ វាជាអ្វីគ្រប់យ៉ាងដែលអ្នកអាចមើលឃើញហើយនិងចុចនៅក្នុងកម្មវិធី Photoshop ។ជាធម្មតាកម្មវិធី Adobe មានលំនាំដើមដែលបានបង្កើតមុនគេ6 មានដូចជា៖ Essentials, 3D, Graphics and Web, Motion, Painting and Photography

របៀបរក្សាទុកឯកសារ ( Save ) ចុច File យកពាក្យថា Save ឬ ( Ctrl + S )

- បន្ទាប់មកជ្រើសរើសទីតាំងសម្រាប់ទុកឯកសារ

- ជ្រើសរើសទីតាំង Drive សម្រាប់ទុកឯកសារ ( Ex: Local Disk D )

- ដាក់ឈ្មោះនៅក្នុងប្រអប់ File Name

-  ជ្រើសរើសយកប្រភេទ File

JPG; ជា Tile សំរេចដោយមិនអាចកបាននៅពេលក្រោយ

PSD, PDD: ជា WE ដែលអាចកបាននៅពេលក្រោយទៀត

- BMI; ជា File ដែលមិនមានស្រមោល

GIF: ជា File ដែលមានចលនាហើយអាចដាក់នៅលើ Webpage បាន.........

## ❧ចំនុចសំខាន់មានដូចខាងក្រោម៖

1. Name : ដាក់ឈ្មោះឱ្យក្រដាសកិច្ចការ (Name Document)
2. Document Type : ប្រភេទ ក្រដាសកិច្ចការ
3. Width: ប្រវែងផ្តេក គិតជា Pixels, inches, cm, mm, points, picas, columns
4. Height: ប្រវែងកំពស់ គិតជាPixels, inches, cm, mm, points, picas, columns
5. Resolution: កំណត់ភាពច្បាស់រូបភាពគិតជា Pixels/inches ឬ pixels/cm
6. Color Mode: កំណត់ប្រភេទពណ៌ទៅឲ្យ Background
7. Background Contents: កំណត់ Background
8. កំណត់រួចរាល់ហើយចុច Ok Button

## របៀបបើក Files (Open File)

ក្នុងកម្មវិធី Adobe Photoshop CC 2021 យើងអាចធ្វើការ Open Files ជាច្រើនដូចជា JPEG, GIF,PSD, Photoshop, Photoshop PDF, Photoshop Raw, PNG...។

### បើកបានគ្រប់រូបភាព គ្រប់ File ទាំងអស់

❶ចុច File Menu => Open...




❷ឬ ប្រើលើ Keyboard (Ctrl + O) រួចបង្ហាញ Dalog box ដូចខាងក្រោម

☞ កម្មវិធីនេះ អាចធ្វើអ្វីៗបានគឺត្រូវមាន Tools ជាចាំបាច់ និង ត្រូវស្វែងយល់ពី Tools ដែលមានឧបករណ៍ ជាច្រើននៅក្នុងនោះ




*<u>បញ្ជាក់</u> : នៅក្នុងឧបករណ៍ខាងលើនេះ គឺនៅមានឧបករណ៍បង្កប់ជាច្រើនទៀត ដោយគ្រាន់តែចុច **Mouse** ស្តាំ លើរូបណាមួយ និងឃើញនូវឧបករណ៍ផ្សេងទៀត ។*

# ការប្រើប្រាស់ Tools និង Selection Tools

នៅក្នុងកម្មវិធី Adobe Photoshop CC 2021 បានបន្ថែមនូវប្រភេទ Tools មួយចំនួនច្រើនជាង Version មុនៗមាន៧ប្រភេទ។

1. Selection tools : ប្រើសម្រាប់ធ្វើការរំកិល Select និងកាត់រូបភាពផ្សេងៗ
2. Crop and slice tools : សម្រាប់កាត់បន្ថយទំហំរូបភាព និងបែងចែករូបភាពភ្ជាប់ជាមួយ Internet
3. Measuring tools : វាស់ប្រវែងទំហំរូបភាព ដកពណ៌និងសរសេរកំនត់សំគាស់ផ្សេងៗ
4. Retouching tools : សម្រាប់លុបឬប៉ះរូបភាពដែលខូចខាតអោយមកជាសភាពស្រស់ស្អាត
5. Painting tools : សម្រាប់ធ្វើការគូស ផាត់ និងចាក់ពណ៌អោយរូបភាព
6. Drawing type tools : សម្រាប់ធ្វើការគូបង្កើតរូបភាព និងសរសេរអក្សរ
7. Navigation tools : សម្រាប់ពង្រីកបង្រួមរូបភាព និងបង្កើតរូបភាពជាលក្ខណៈ3D

## Selection tools

| Icons | Name | Shortcut | Description |
|---|---|---|---|
|  | Move | V | រំកិលរូបភាព អក្សរ ឬតំបន់ដែលបានSelect |
|  | Rectangular Marquee | M | Select រូបភាពជារាងការេ ឬចតុកោណ |
|  | Elliptical Marquee | M | Select រូបភាពជារាងមូល ឬវង្វង់ |
|  | Single Column Marquee | | Select រូបភាពទំហំ1Pixel ផ្ដេក |
|  | Single Row Marquee | | Select រូបភាពទំហំ1Pixel បញ្ឈរ |
|  | Lasso | L | Select រូបភាពទៅតាមការអូសរបស់ Mouse |
|  | Polygonal Lasso | L | Select រូបភាពដោយដៅចំនុចមួយៗជាបន្ទាត់ត្រង់ |
|  | Magnetic Lasso | L | Select រូបភាពដោយធក់តាមពណ៌ |
|  | Quick Selection | W | Select រូបភាពមានពណ៌ប្រហែលគ្នាជាបន្តបន្ទាប់ |
|  | Magic Wand | W | Select រូបភាពណាមានពណ៌ប្រហែលគ្នា |
|  | Object Selection | W | Select រូបភាពតាមការ Selectលើ Object |

## Crop and slice tools

| Icons | Name | Shortcut | Description |
|---|---|---|---|
| | Crop | C | កាត់យកផ្នែកណាមួយនៃរូបភាពដែលចង់បាន |
| | Perspective Crop | C | កាត់យករូបភាពដែលចង់បានដោយពង្រីកទំហំម្ខាងនៃរូបភាព |
| | Slice | C | Select ផ្នែកណាមួយនៃរូបភាពសម្រាប់Linkជាមួយ Website |
| | Slice Select | C | រំកិលផ្នែកដែលបាន Select ដោយ Slice tool |

## Measuring tools

| Icons | Name | Shortcut | Description |
|---|---|---|---|
| | Eyedropper | I | ចម្លងពណ៌ក្នុងរូបភាពទៅក្នុង Foreground color |
| | Color Sampler | I | សម្គាល់ពណ៌ដែលមានៅក្នុងរូបភាព |
| | Ruler | I | វាស់ប្រវែងនៅក្នុងរូបភាព |
| | Note | I | សរសេរសម្គាល់នៅក្នុងរូបភាព |
| | Count | I | សម្គាល់ពណ៌ដែលមាននៅក្នុងរូបភាព |

## Retouching tools

| Icons | Name | Shortcut | Description |
|---|---|---|---|
| | Spot Healing Brush | J | លុបបំបាត់ស្នាមចំនុចតូចៗដែលមាននៅលើរូបភាព |
| | Healing Brush | J | ផ្ចិតយកផ្នែកណាមួយនៃរូបភាពទៅបន្ថែមឱ្យផ្នែកមួយទៀត |
| | Patch | J | Select យកផ្នែកណាមួយនៃរូបភាពទៅប៉ះឱ្យផ្នែកមួយទៀត |
| | Content Aware Move | J | Select យកផ្នែកណាមួយនៃរូបភាពទៅប៉ះឱ្យផ្នែកមួយទៀត |

| | | | |
|---|---|---|---|
| | Red Eye | J | លុបបាត់ចំណុចក្រហមក្នុងកែវភ្នែក |
| | Clone Stamp | S | ផ្តិតយកផ្នែកណាមួយនៃរូបភាពទៅបន្ថែមផ្នែកណាមួយ |
| | Pattern Stamp | S | ផ្តិតពណ៌រូបភាពទៅតាម Pattern |
| | Eraser | E | លុបផ្នែកផ្សេងៗនៅក្នុងរូបភាព |
| | Background Eraser | E | លុបផ្នែកផ្សេងៗនៅក្នុងរូបភាពរួមទាំង Background ផងដែរ |
| | Magic eraser | E | លុបតំបន់ណាមួយក្នុងរូបភាពដែលមានពណ៌ប្រហែលគ្នា |
| | Blur | | ផាត់រូបភាពឲ្យមានលក្ខណៈព្រិល ឬស្រអាប់ |
| | Sharpen | | ផាត់រូបភាបឲ្យមានលក្ខណៈគ្រើម |
| | Smudge | | ផាត់រូបភាពឲ្យមានលក្ខណៈជាពណ៌ចំរុះ |
| | Dodge | O | ធ្វើឲ្យរូបភាពភ្លឺហើយស |
| | Burn | O | ធ្វើឲ្យរូបភាពងងឹតហើយខ្មៅ |

## Painting tools

| Icons | Name | Shortcut | Description |
|---|---|---|---|
| | Brush | B | ផាត់ពណ៌ក្នុងរូបភាព |
| | Pencil | B | គូរូបឬពណ៌ក្នុងរូបភាព |
| | Color Replacement | B | បន្ថែមពណ៌ស្តើងៗឲ្យរូបភាព |
| | History Brush | Y | ផាត់លើរូបភាបដើម្បីត្រឡប់មកសភាពដើមវិញ |
| | Art History Brush | Y | ផាត់ឲ្យរូបភាពលាយពណ៌បញ្ចូលគ្នា |
| | Gradient | G | លាយពណ៌ចំរុះដើម្បីចាក់លើផ្ទាំងរូបភាព |

| | | | |
|---|---|---|---|
|  | Paint Bucket | G | ចាប់ពណ៌មួយៗលើផ្ទាំងរូបភាព |

## Drawing and type tools

| Icons | Name | Shortcut | Description |
|---|---|---|---|
|  | Pen | P | បង្កើត Path ដោយដៅជាចំនុចៗហើយពត់ជារាងផ្សេងៗ |
|  | Freeform Pen | P | បង្កើត Path ទៅតាម Mouse ដែលបានអូស |
|  | Add Anchor Point | | បន្ថែមចំនុចទៅឱ្យ Path ដើម្បីពត់រាងផ្សេងៗ |
|  | Delete Anchor Point | | លុបចំនុចដែលមាននៅលើ Path |
|  | Convert Point | | ពត់ចំនុចនៅលើ Path ទៅជារាងផ្សេងៗ |
|  | Horizontal Type | T | សរសេរអក្សរទម្រង់ផ្ដេក |
|  | Vertical Type | T | សរសេរអក្សរទម្រង់បញ្ឈរ |
|  | Horizontal Type Mask | T | សរសេរអក្សរជាលក្ខណៈ Select តាមទម្រង់ផ្ដេក |
|  | Vertical Type Mask | T | សរសេរអក្សរជាលក្ខណៈ Select តាមទម្រង់បញ្ឈរ |
|  | Path Selection | A | រំកិល Path or Shape |
|  | Direct Selection | A | ពត់ Path or Shape |
|  | Rectangle | U | បង្កើត Shape រាងបួនជ្រុង |
|  | Rounded Rectangle | U | បង្កើត Shape រាងបួនជ្រុង មានជ្រុងកែងមូល |
|  | Ellipse | U | បង្កើត Shape រាងវង្វង់មូល |
|  | Polygon | U | បង្កើត Shape រាងពហុកោណ ឬផ្កាយ |

| | | | |
|---|---|---|---|
| | Line | U | បង្កើត Shape រាងបន្ទាត់ត្រង់ |
| | Custom Shape | U | បង្កើត Shape ជារូបផ្សេងៗដែលមានស្រាប់ |

## Navigation

| Icons | Name | Shortcut | Description |
|---|---|---|---|
| | Hand | H | រំកិលរូបភាពដើម្បីមើល |
| | Rotate View | R | រំកិលត្រឡប់រូបភាព |
| | Zoom | Z | ពង្រីកបង្រួមរូបភាព |




# ការប្រើប្រាស់ Undo, Redo, Cut, Copy និងការកំណត់ទំហំ Image

## ១. ការប្រើប្រាស់ Undo

ត្រូវបានប្រើសម្រាប់ត្រឡប់ទៅកាន់ការងារដែលយើងបានធ្វើទៅក្រោយមួយជំហាន ឬមួយចំហានវិញ។

❶ ចុច Edit Menu => Undo( Ctrl + Z )




## ២. ការប្រើប្រាស់ Step Backward

ត្រូវបានប្រើសម្រាប់ត្រឡប់ទៅកាន់ការងារដែលយើងបានធ្វើទៅក្រោយម្តងមួយជំហាន។

❶ ចុច Edit Menu => Step Backward( Alt + Ctrl + Z )




## ៣. ការប្រើប្រាស់ Step Forward

ត្រូវបានប្រើសម្រាប់ត្រឡប់ទៅកាន់ការងារដែលយើងបានធ្វើទៅមុខម្តងមួយជំហាន។

❶ ចុច Edit Menu => Step Forward( Shift + Ctrl + Z )




## ៤. ការប្រើប្រាស់ Cut

គឺជាប្រើសម្រាប់លុបតំបន់ដែលបាន Select ហើយរក្សាទុកក្នុង Clipboard ដែលជាកន្លែងមួយសម្រាប់ចងចាំទុកនូវអ្វីដែលយើងបាន Cut។បង្ហាញមកវិញនៅពេលយើង Paste

❶ ចុច Edit Menu=> Cut( Ctrl + X )




## ៥. ការប្រើប្រាស់ Copy

គឺជាប្រើសម្រាប់ចម្លងតំបន់ដែលបាន Select ហើយរក្សាទុកក្នុង Clipboard ដែលជាកន្លែងមួយសម្រាប់ចងចាំទុកនូវអ្វីដែលយើងបាន Copy ។ បង្ហាញមកវិញនៅពេលយើង Paste

❶ ចុច Edit Menu => Copy( Ctrl + C )




## ៦. របៀបកំណត់ Mode ឱ្យ Image

ទំហំនិងប្រភេទ Mode មានដូចជា:

- Bitmap: ជាប្រភេទរូបភាពធម្មតាដែលមានទំហំតូច
- Grayscale : ជាប្រភេទរូបភាពដែលមានពណ៌ខ្មៅ
- Indexed Color: ជាប្រភេទរូបភាពធម្មតាដែលមានទំហំតូចស្រដៀងគ្នានឹង Bitmap ដែល
- RGB ( Red Green Blue ): ជាប្រភេទរូបភាពដែលប្រើជាមួយនឹងការ Print ឬរូបថតជាដើម

- CMYK Color ( Cyan Magenta Yellow Black ): សម្រាប់ប្រើជាមួយការបោះពុម្ព
- Image Menu => Mode => ជ្រើសរើស Mode

## ៧. របៀបប្រើប្រាស់ Image Size

ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកែប្រែទំហំរបស់ Image ទៅតាមតម្រូវការដែលយើងចង់បាន ដោយក្នុងនោះយើងអាចធ្វើការកែប្រែទាំងទំហំ និង Resolution របស់ Image នោះ។

❶ ចុច Image Menu => Image Size( Alt + Ctrl + I )




## ៨. របៀបប្រើប្រាស់ Canvas Size

ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការបន្ថែមទំហំជុំវិញបន្ថែមទៅទៀតឲ្យImage ដោយក្នុងនោះទំហំដែលបន្ថែមអាចយកពណ៌ទៅតាមពណ៌របស់ Background ឬForeground។

❶ ចុច Image Menu => Canvas Size( Alt + Ctrl + C )





## ៩. របៀបប្រើប្រាស់ Image Rotation

❶ ចុច Image Menu => Image Rotation

✍ជ្រើសរើស

- $180^0$ : សម្រាប់បង្វិល Image $180^0$
- $90^0$ Clockwise : សម្រាប់បង្វិលទៅស្តាំ $90^0$
- $90^0$ Counter Clockwise : សម្រាប់បង្វិលទៅឆ្វេង $90^0$
- Flip Canvas Horizontal : សម្រាប់ត្រឡប់ Image បញ្ច្រាស់ពីឆ្វេងទៅស្តាំឬពីស្តាំទៅឆ្វេង
- Flip Canvas Vertical : សម្រាប់ត្រឡប់ Image បញ្ច្រាស់ពីលើចុះក្រោម ឬពីក្រោមឡើងលើ

Flip Canvas Horizontal



## ១០. របៀប Duplicate Image

សម្រាប់ធ្វើការ Copy រូបភាពមួយចេញពីរូបភាពដើមបន្ថែមទៀត ដើម្បីចៀសវាងនូវកំហុសដែលអាចនឹងកើមានឡើង។

❶ Image Menu => Duplicate

❷ ដាក់ឈ្មោះថ្មី => Ok



# លំហាត់អនុវត្តទី១ ការបង្កើតឈ្មោះជាអក្សរភ្លើង

## ជំហានទី១

- បង្កើតក្រដាសកិច្ចការថ្មីមួយសិន ( A4 ) ➔ ចុច Ctrl + N រួចចុចត្រង់ Print យក ប្រភេទក្រដាស A4
- យកពណ៌ Background ពណ៌ខ្មៅ
- សរសេរឈ្មោះរបស់អ្នក យកពណ៌ សរ

ឧទាហរណ៍ 


- ត្រូវ Copy ឈ្មោះរបស់អ្នកដែលបានសរសេរនោះ រួចចុចបិទភ្នែកវា (Ctrl + J)
- ត្រូវចុច Merge ឈ្មោះរបស់អ្នកដែលមិនបានបិទភ្នែកជាមួយ Background ពណ៌ខ្មៅ ទៅជា Layer តែមួយ ដោយគ្រាន់តែ ចុច Select លើ Layer ឈ្មោះរបស់អ្នក និងចុច Key Ctrl ឱ្យជាប់ បន្ទាប់មកយក Mouse ចុចលើ Background ពណ៌ខ្មៅ នោះយើងវានិង Select Layer ទាំងពីរ
- បន្ទាប់មក ចុច Key Ctrl + E
- បន្ទាប់មក ចុច Tap Image រួចយកពាក្យ Image Rotation

  រួចចុច ពាក្យ $90^0$ Counter Clockwise
- យើងនិងទទួលបានរូបដូចខាងក្រោម




- បន្ទាប់មកចុច Tap Filter ចុចយកពាក្យ Stylize រួចចុចពាក្យ Wind




- យើងនិងទទួលបានរូបដូចខាងក្រោម




- បន្ទាប់មកចុច Tap Filter ចុចយកពាក្យ Wind ( Alt + Ctrl + F ) ដើម្បីបន្ថែមផ្សេង
- បន្ទាប់មក ចុច Tap Image រួចយកពាក្យ Image Rotation

  រួចចុច ពាក្យ $90^0$ Clockwise



❖ បន្ទាប់មកចុច Tap Filter ចុចយកពាក្យ Blur ហើយចុច Gaussian Blur




❖ យើងនិងទទួលបានរូបដូចខាងក្រោម






❖ បន្ទាប់មកចុច Tap Filter ចុចយកពាក្យ Liquify... ( Shift + Ctrl + X )



❖ កន្លែង Brush Tool Options ( Size យក 35 ) រួចយកមកគូសលើឈ្មោះ ➔ ចុច OK




❖ បន្ទាប់មក ចុច Tap Image រួចយកពាក្យ Adjustments រួច Hue/Saturation... ( Ctrl + U )




❖ ចុច✓ ត្រង់ពាក្យ Colorize កន្លែង Hue យក +40 និង Saturation យក +100 ➔ ចុច OK



➢ ត្រូវ Copy Lager នោះទុក (Ctrl + J)

❖ បន្ទាប់មកចុច Tap Image រួចយកពាក្យ Adjustments រួច Hue/Saturation… ( Ctrl + U ) ម្តងទៀត

❖ កន្លែង Hue យក -40 និង Saturation យក +100 ➔ ចុច OK




❖ ឈរលើ Layer ដែលយើង Copy រួចចុចពាក្យ Normal ហើយចុច ពាក្យ Color Dodge




❖ ត្រូវចុច Merge Layer ដែលបាន Copy ជាមួយ Layer ដើមឱ្យទៅជា Layer តែមួយ ដោយគ្រាន់តែ ចុច Select លើ Layer ដែលបាន Copy និងចុច Key Ctrl ឱ្យជាប់ បន្ទាប់មកយក Mouse ចុចលើ Layer ដើម នោះយើងវានិង Select Layer ទាំងពីរ

❖ បន្ទាប់មក ចុច Key Ctrl + E

❖ ត្រូវចុចបើកភ្នែក Layer ឈ្មោះរបស់អ្នកដែលបាន Copy លើកមុនមកវិញ




❖ ធ្វើការប្តូរពណ៌អក្សរទៅតាមចំណង់ចំនូលចិត្តរបស់អ្នក




## លំហាត់អនុវត្តទី២ ការបង្កើតឈ្មោះជាអក្សរមាស

### ជំហានទី១

- បង្កើតក្រដាសកិច្ចការថ្មីមួយសិន
- ចុច Ctrl + N រួចចុចត្រង់ (Film & Video) យកប្រភេទក្រដាស HDTV 1080P
- យកពណ៌ Background ពណ៌ សរ
- សរសេរឈ្មោះរបស់អ្នក យកពណ៌ លឿង

ឧទាហរណ៍



- ចុច ឈរ នៅលើឈ្មោះរបស់យើង រួចចុច FX រួចចុច យកពាក្យ Bevel & Emboss




- សូមជ្រើសរើសពាក្យ ពណ៌ និងបញ្ចូល លេខ ឱ្យដូចក្នុងរូបខាងក្រោម៖




- ចំពោះកន្លែងពណ៌ សូមជ្រើសរើសតាមគម្រូខាងក្រោមនេះ






❖ ការងារដែលយើងទទួលបាន






❖ បន្ទាប់មកទៀត ឈរ នៅលើឈ្មោះរបស់យើង រួចចុច FX ដដែលរួចចុច យកពាក្យ Color Overlay

❖ ត្រង់ Blend Mode យកពាក្យ Darker Color

❖ ត្រង់ពណ៌ ត្រូវចុចលើវា រួចចុចយកពណ៌ លឿង ហើយត្រូវបញ្ចូលលេខ ពី H ដល់ B ឱ្យដូចក្នុងរូប

❖ ត្រង់ Opacity យក 35%

❖ រួចចុច OK




❖ បន្ទាប់មកទៀត ឈរ នៅលើឈ្មោះរបស់យើង រួចចុច FX ដដែលរួចចុច យកពាក្យ Drop Shadow

❖ ត្រង់ Blend Mode យកពាក្យ Normal ត្រង់ពណ៌ ត្រូវចុចលើវា រួចចុចយកពណ៌ ខ្មៅ

❖ ត្រង់ Opacity យក 100%

❖ ត្រង់ Distance យក 11px / ត្រង់ Spread យក 22% / ត្រង់ Size យក 0px

❖ រួចចុច OK



# លទ្ធផលដែលទទួលបាន




## សំហាត់អនុវត្តទី៣ ការបង្កើតឈ្មោះជាអក្សរ 3D

### ជំហានទី១

- បង្កើតក្រដាសកិច្ចការថ្មីមួយសិន (A4) ➔ ចុច Ctrl + N រួចចុចត្រង់ Print យក ប្រភេទក្រដាស A4
- យកពណ៌ Background ពណ៌ សរ
- សរសេរឈ្មោះរបស់អ្នក យកពណ៌ បៃតង

ឧទាហរណ៍




- ត្រូវ Copy ឈ្មោះរបស់អ្នកដែលបានសរសេរនោះទុក (Ctrl + J) រួចចុចប្តូរពណ៌ទៅជាពណ៌ ខ្មៅ
- រួចចុចទាញឈ្មោះដែលបាន Copy ពណ៌ ខ្មៅ និងមកដាក់ខាងក្រោម ឈ្មោះដើម
- ចុចបិទភ្នែក Layer ឈ្មោះដើម
- រួចហើយឈរនៅលើឈ្មោះដែលបាន Copy ពណ៌ ខ្មៅ រួចចុច Right-Click (ម៉ៅស្តាំ)
- ចុចយកពាក្យ Convert to Smart Object




- ❖ ឈរនៅលើឈ្មោះដែលបាន Copy ពណ៌ ខ្មៅ ដែលយើងបាន Convert to Smart Object និងដដែល
- ❖ រួចចុច Alt + Arrow Left And Down ចុចយកវាឱ្យបាន 10ដង ស្មើនិង 30 Layer Smart Object



❖ ចុចបើកភ្នែក Layer ឈ្មោះដើម ដែលយើងបានចុចបិទភ្នែកកាលលើកមុនមកវិញ

❖ បន្ទាប់មក ចុច Right-Click ( ម៉ៅស្តាំ ) លើ Smart Object ទី៣០

❖ ចុចយកពាក្យ Blending Options…




❖ រួចចុច ត្រង់ពាក្យ Drop Shadow

❖ រួចសូមជ្រើសរើសយក លេខ ដូចក្នុង រូប ខាងក្រោម

❖ ជ្រើសរើសត្រឹមត្រូវតាម រូប ហើយ ចុច OK



# លិទ្ធផលដែលទទួលបាន

# SovanReak



## លំហាត់អនុវត្តទី៤ ការកាត់រូបចេញ Background



រូបភាពទី១



រូបភាពទី២



រូបភាពទី៣

- ❖ បង្កើតក្រដាសកិច្ចការថ្មីមួយសិន
- ❖ ➔ ចុច Ctrl + N រួចចុចត្រង់ Web យកប្រភេទក្រដាស Web Most Common
- ❖ យកពណ៌ Background ពណ៌ សរ
- ❖ ទាញរូបទាំង៣ បញ្ចូលក្នុងកម្មវិធី សម្រាប់ធ្វើការ កាត់ ត
- ❖ មកដល់ចំណុចនេះ ដើម្បីធ្វើការ កាត់ ត បានយើងត្រូវប្រើប្រាស់ Pen Tools (P)




## ខាងក្រោមនេះលិទ្ធផលដែលទទួលបាន



## លំហាត់អនុវត្តន៍ទី៥ ការធ្វើ Logo សម្រាប់នំបិណ្ឌ វគ្គ១




- បង្កើតក្រដាសកិច្ចការថ្មីមួយសិន
- ➔ ចុច Ctrl + N រួចចុចត្រង់ Art & Illustration យកប្រភេទក្រដាស 2000 pixel grid
- យកពណ៌ Background ពណ៌ សរ
- ទាញរូបទាំងអស់ដែលគេឱ្យ បញ្ចូលក្នុងកម្មវិធី សម្រាប់ធ្វើការ កាត់ ត

នេះលិទ្ធផល

ដែលទទួលបាន



## លំហាត់អនុវត្តទី៦ ការធ្វើ Poster សម្រាប់ភ្ជុំបិណ្ឌ ខគ្គ២

- ❖ បង្កើតក្រដាសកិច្ចការថ្មីមួយសិន
- ❖ ➔ ចុច Ctrl + N រួចចុចត្រង់ Art & Illustration យកប្រភេទក្រដាស Poster
- ❖ យកពណ៌ Background ពណ៌ សរ
- ❖ ទាញរូបទាំងអស់ដែលគេឱ្យ បញ្ចូលក្នុងកម្មវិធី សម្រាប់ធ្វើការ កាត់ ត

រូបភាពដែលគេផ្ដល់ឱ្យ















រូបពពក






នេះលិទ្ធផលដែលទទួលបាន

## លំហាត់អនុវត្តទី៧ ការធ្វើ Poster សម្រាប់ភ្ជុំបិណ្ឌ ខគ្គ៣

- បង្កើតក្រដាសកិច្ចការថ្មីមួយសិន
- ➔ ចុច Ctrl + N រួចចុចត្រង់ Art & Illustration យក Width 17cm  X  Height 17Cm
- យកពណ៌ Background ពណ៌ ទឹកសមុទ្រ
- ទាញរូបទាំងអស់ដែលគេឱ្យ បញ្ចូលក្នុងកម្មវិធី សម្រាប់ធ្វើការ កាត់ ត
- ដំបូងទាញរូប BG ចូល បន្ទាប់មករូបវត្ត ចុច Right-Click (ម៉ៅស្តាំ) លើរូបវត្ត ហើយដាក់វាទៅជា Smart Object យកកម្រិតច្បាស់តែ 20% បានហើយ
- ត្រង់ស្លឹកចេក + ស្លឹកដូង ចុច Right-Click (ម៉ៅស្តាំ) លើរូបហើយដាក់វាទៅជា Smart Object ចុច Tap Filter ចុចយកពាក្យ Blur ហើយចុច Gaussian Blur យក 10
    - ✓ ពាក្យបុណ្យភ្ជុំបិណ្ឌ ត្រូវធ្វើវាទៅជាអក្សរមាស

## រូបភាពដែលគេផ្តល់ឱ្យ





# នេះលិទ្ធផលដែលទទួលបាន




# មជ្ឈមណ្ឌលកុំព្យូទ័រ និងជំនាញបច្ចេកវិទ្យា សុវណ្ណរក្ស

## លំហាត់អនុវត្តទី៨ ការ ឌីសាញ Poster កាន់បុណ្ឌ & ភ្ជុំបិណ្ឌ វគ្គ៤

បង្កើតក្រដាសកិច្ចការថ្មីមួយសិន

- ➔ ចុច Ctrl + N រួចចុចត្រង់ Art & Illustration យក 2000 X 2000 Pixels
- យកពណ៌ Background ពណ៌ សរ
- ទាញរូបចូលក្នុងក្រដាសកិច្ចការ























# រូបភាពខាងលើជាធាតុផ្សំដែលគេផ្ដល់ឱ្យ

រូបភាពព្រះវិហារត្រូវកាត់យកតែព្រះវិហារមកប្រើ ហើយចុច Tap Filter ចុចយកពាក្យ Blur ហើយចុច Gaussian Blur ដាក់លេខតាមចិត្តរបស់អ្នកគិតថា Blur ស្អាត

❖ មកដល់ចំណុចរូបវត្ត ចុច Right-Click (ម៉ៅស្តាំ) លើរូបវត្ត ហើយដាក់វាទៅជា Smart Object ហើយយករូប ដើមត្នោត មកដាក់ពីក្រោយវត្ត ហើយចុច Tap Filter ចុចយកពាក្យ Blur ហើយចុច Gaussian Blur ដាក់លេខតាមចិត្តរបស់អ្នកគិតថា Blur ស្អាត

មកដល់រូប ស្លឹកចេក + ស្លឹកដូង និងរូប ធាងចេក ក៏ចុច Tap Filter ចុចយកពាក្យ Blur ហើយចុច Gaussian Blur ដាក់លេខតាមចិត្តរបស់អ្នកគិតថា Blur ស្អាត ផងដែរ៕

## រូបភាពដែលយើង ឌីសាញ រួច



## លំហាត់អនុវត្តទី៩ ការធ្វើ Poster សម្រាប់ភ្ជុំបិណ្ឌ ខគ្គ៥ សម្រាប់ Cover FB

The recommended Facebook cover photo size is 820 x 312 pixels for desktop and 640 × 360 pixels for mobile devices.

បង្កើតក្រដាសកិច្ចការថ្មីមួយសិន

- ➔ ចុច Ctrl + N រួចចុចកំណត់ក្រដាសកិច្ចការ យក 820 x 312 pixels សម្រាប់កុំព្យូទ័រ
- យកពណ៌ Background ពណ៌ សរ
- ទាញរូបចូលក្នុងក្រដាសកិច្ចការ
- ចំពោះអក្សរ ធ្វើជាអក្សរមាស និងអក្សរ 3D







រូបភាពដែលគេផ្តល់ឱ្យ











ពពក



# រូបដែលទទួលបានក្រោយការ ឌីសាញ



## លំហាត់អនុវត្តទី១០ ការធ្វើ អក្សរ ត្រែត តាមម៉ូត ផ្លូវ

- ➢ រួចទាញរូប ផ្លូវ ដែលគេផ្តល់ឱ្យចូល
- ➢ សរសេរ ឈ្មោះ ឬអក្សរដែលអ្នកចង់សរសេរ យកពណ៌ សរ
- ❖ ចុច Right-Click ( ម៉ៅស្តាំ ) យកពាក្យ Select Pixels រួចចុច Ctrl + C
- ❖ បន្ទាប់មក ចុច បន្ថែម Layer រួចចុច បិទ ភ្នែក Layer ឈ្មោះ
- ❖ បន្ទាប់មកទៀត ចុច Ctrl + D
- ❖ ចុច Tab Fiter រួចចុចយកពាក្យ Vanishing Point......



❖ បន្ទាប់មកទៀត ប្រើ Create Plane Tool ( C ) គូសត្រូវផ្លូវ




❖ រួចចុច Ctrl + V ហើយចុច Ctrl + T ពង្រីក ពង្រួមរូប



រួចចុច Right-Click ( ម៉ៅស្តាំ ) យកពាក្យ Blending Options



# នេះជារូបភាពដែលយើងបាន ឌីសាញ រួច




## លំហាត់អនុវត្តន៍ទី១១ ការប្រើប្រាស់ ប្រភេទ Retouching Tools និងMeasuring Tools

១. ការប្រើប្រាស់ Spot Healing Brush Tool ( J )




❶ Spot Healing Brush Tool: ប្រើប្រាស់ដើម្បីធ្វើការលុបចំនុចផ្សេងៗដែលមាននៅក្នុងរូបភាពជាពិសេស ស្នាមមុនប្រជ្រុយ ឬស្នាមជាំជាចំនុចផ្សេងៗ។

❷ Healing Brush Tool: ប្រើប្រាស់ដើម្បីធ្វើការលុបតំបន់ណាមួយដែលមិនត្រូវការចេញពីក្នុងរូបភាពដោយដំណើរការរបស់វាគឺចំលងយកពណ៌ដែលត្រូវការនៅក្នុងរូបភាពទៅជំនួសពីលើត្រង់តំបន់ដែលមិនត្រូវការ។

❸ Patch Tool: ប្រើប្រាស់ដើម្បីធ្វើការលុបតំបន់ណាមួយដែលមិនត្រូវការចេញពីក្នុងរូបភាពដោយដំណើរការរបស់វាគឺចំលងយកពណ៌ដែលត្រូវការនៅក្នុងរូបភាពទៅប៉ះពីលើដំបន់ដែលមិនត្រូវការ។

❹ Content-Aware Move Tool: ប្រើប្រាស់ដើម្បីធ្វើការយកផ្ទៃរូបភាពពីតំបន់មួយទៅជំនួសផ្ទៃរូបភាពមួយដោយដំណើរការរបស់វាគឺចំលងយកពណ៌ដែលត្រូវការនៅក្នុងរូបភាពទៅប៉ះពីលើតំបន់ដែលមិនត្រូវការ។

❺ Red Eye Tool: ប្រើប្រាស់ដើម្បីធ្វើការលុបចំនុចពណ៌ដែលមាននៅក្នុងភ្នែក។

## អនុវត្ត១

❶ បើករូបភាព

❷ យក Spot Healing Brush Tool មកប្រើ





## លំហាត់អនុវត្តទី១២ ការបង្កើត ព្រះអាទិត្យ លើរូបភាព

❶ បើកយករូបភាព



ចុចលើ Filter Menu => Render =>Lens Flare…




+ Lens Type:

- 50-300mm Zoom: ថ្ងៃចាំងពណ៌ក្រហមដោយមានស្រមោល
- 35mm Prime: ថ្ងៃចាំងពណ៌ក្រហមដោយមានស្រមោលខ្លាំង
- 105mm Prime: ថ្ងៃចាំងពណ៌សដោយមានស្រមោលស្រាល
- Movie Prime: ថ្ងៃចាំងពណ៌ក្រហមដោយមានស្រមោលធូតៗ



❖ ចុច Ctrl + L សម្រាប់ កែពណ៌ បន្ថែម ឬចុច Ctrl + M



## លំហាត់អនុវត្តទី១៣ ការការប្រើប្រាស់ Blur Tool




❶ Blur Tool: ប្រើប្រាស់ដើម្បីធ្វើអោយរូបភាពមានភាពស្រអាប់ព្រាលៗ។

❷ Sharpen Tool: ប្រើប្រាស់ដើម្បីឈូសរូបភាពឱ្យដាច់ពណ៌ដើមហើយផ្លាស់ប្តូរទៅជាពណ៌មួយផ្សេងទៀត។

❸ Smudge Tool: ត្រូវបានប្រើប្រាស់ដើម្បីធ្វើការទាញតំបន់ណាមួយរបស់រូបភាព។

## អនុវត្ត

❶ បើករូបភាព

❷ យក Blur Tool មកប្រើ


Blur Tool
Sharpen Tool
Smudge Tool



## លំហាត់អនុវត្តទី១៤ ការធ្វើ អក្សរ តាមធម្មជាតិ

- រួចទាញរូប ផ្លូវ ដែលគេផ្តល់ឱ្យចូល
- ចុច Copy Layer រូបភាព រួចចុច បិទភ្នែក រូបភាព Layer ដែលមាន កន្ទុយ Copy
- ប្រើ Tools មានអក្សរ T មកសរសេរ ឈ្មោះ ឬអក្សរដែលអ្នកចង់សរសេរ យកពណ៌ សរ




- ឈរលើ Layer រូបភាព ដែលជាប់ សោរ រួចចុច Right-Click ( ម៉ៅស្តាំ ) Tab ខាងក្រោយយក លេខ 0 សរ ខ្មៅ យកពាក្យ Hue/Saturation……




- ចុចយកកម្រិតពណ៌ដូចក្នុងរូបខាងក្រោម




- ❖ មកឈរ លើ Layer អក្សរ វិញ ហើយ Right-Click ( ម៉ៅស្តាំ ) យកពាក្យ Rasterize Type
- ❖ រួចចុច Copy អក្សរ និងមួយទុក
- ❖ ឈរ លើ Layer អក្សរ ដែលមិនមាន កន្ទុយ Copy រួចចុច Ctrl + T
- ❖ ត្រឡប់មកមើល កន្លែង ឌីសាញ យើង វិញ រួចចុច ម៉ៅស្តាំ លើអក្សរ យក Flip Vertical




- ទាញ តម្រៀប វាឱ្យស្មើរគ្នា រួច ម៉ៅស្តាំ យកពាក្យ Perspective




រួចចុច Enter ហើយទៅចុច បិទ ភ្នែក Layer វា បន្ទាប់មកទៅចុច បើកភ្នែក Layer រូបភាព ដែលបិទភ្នែក

ឈរនៅលើ Layer រូបភាព រួចចុច ម៉ៅស្តាំ យកពាក្យ Create Clipping Maske

ឈរនៅលើ Layer អក្សរ ដែលមិនបានបិទភ្នែកវា មានកន្ទុយ Copy យកពាក្យ Blending Options……

រួចចុច យកពាក្យ Stroke កន្លែងពណ៌ យកពណ៌ សរ

បន្ទាប់មក ចុច យកពាក្យ Inner Glow រួច ចុចយកតាមដូចរូបខាងក្រោម




បន្ទាប់មក ចុច យកពាក្យ Outer Glow រួច ចុចយកតាមដូចរូបខាងក្រោម




បន្ទាប់មកទៀត ចុច បើកភ្នែក Layer អក្សរ រួចចុច Tap Filter ចុចយកពាក្យ Blur ហើយចុច Gaussian Blur ដាក់លេខតាមចិត្តរបស់អ្នកគិតថា Blur ស្អាត ផងដែរ៕

រូបភាពទទួលបាន

ក្រោយ ឪសាញ



## លំហាត់អនុវត្តទី១៥ ការបង្កើតឈ្មោះជាអក្សរកោងសម្រាប់ធ្វើ Logo

- បង្កើតក្រដាសកិច្ចការថ្មីមួយសិន ➔ ចុច Ctrl + N
- ចុច Art & Illustration យកប្រភេទក្រដាស 2000 pixel grid
- យកពណ៌ Background ពណ៌ ស
- រួចយក Tools មកប្រើ Ellipse មកគូសជារាងរង្វង់
- រួចចុច ចាក់ពណ៌ យកពណ៌ប្រផេះ
- ចុច Copy Ellipse 1 ចុច Ctrl + T បង្រួមឱ្យតូចល្មមស្អាត ចាក់ពណ៌ផ្សេងពីពណ៌មុន
- ពេលចុច បង្រួមឱ្យតូច ចុច Alt ផង ចាំចុចបង្រួម
- ចុច Copy Ellipse 1 ម្តងទៀត ចុចបង្រួមឱ្យតូចល្មមស្អាតដដែរ រួចចាក់ពណ៌ផ្សេងពីពណ៌មុន
- ទាញរូបណាមួយ តំណាង ថាជានិមិត្តសញ្ញា ដែលអ្នកចង់យកមកធ្វើជា LOGO



- ទាញបន្ទាប់មកតម្រៀបឱ្យចំកណ្តាល ដើម្បីងាយស្រួលក្នុងការសរសេរអម្បរ
- ដើម្បីសរសេ អក្សរឱ្យកោង បាន យើងត្រូវប្រើប្រាស់ Tools Ellipse យកវាមកគូសឱ្យប៉ុនរង្វង់ចាស់ជាមុនសិន
- ប្រើ Tools អក្សរ T មកសរសេរ សូមចុចឱ្យចំខ្សែបន្ទាត់ជួរឈរសិនចាំសរសេរ

- បើចង់បានអក្សរកោងនៅខាងក្រោមវិញ ត្រូវ ប្រើ Tools អក្សរ T មកសរសេរ រួច
- ត្រូវប្រើ Tools Path Selection ដែលនៅពីក្រោម Tools អក្សរ T មករំកិល អក្សរ
- បើនៅតែ រំកិល អក្សរ មិនស្អាត មិនត្រូវតាមរង្វង់ទៀត
- ត្រូវចុច Ctrl + T រួចចុច Ctrl ឱ្យជាប់ ចាំចុច ទាញសារេ តាមគែម

# ក្រោយ ឪសាញ រួច

# លំហាត់អនុវត្តទី១៦ ការសរសេរអក្សរជុំវិញរូបរត់តាមបន្ទាត់

- ដំបូងទាញរូបភាពដើមចូល
- ចុច Tab Select នៅផ្នែកខាងលើ រួចចុច យកពាក្យ Subject
- បន្ទាប់មក ចុច Tab Select នៅផ្នែកខាងលើដដែល រួចចុច យកពាក្យ Modify ➔ Expand……




- ចុច តម្លើងលេងដល់ 50 រួច ចុច OK



- ➢ បន្ទាប់មកទៀត យើងចុច Tab Select នៅផ្នែកខាងលើដដែល
- ➢ រួចចុចយកពាក្យ Modify ➔ Smooth…… វិញម្តង




- ➢ តម្លើងចំនួនលេងឡើងទៅដល់ 100 រួច ចុច OK



❖ សូមចុចទៅប្រើ Tools Lasso រួចមក ចុច Right-Click (ម៉ៅស្តាំ) លើរូប ហើយចុចយកពាក្យ




➢ ចុច យកលេខ 2.0 ដដែល រួច ចុច OK



- បន្ទាន់មកទៀត សូមប្រើ Tools Horizontal Type អក្សរ T មកដាក់ឱ្យចំ ចំណុច ចុច ពណ៌ខៀវ រួចអ្នកអាចសរសេរ អ្វីដែលអ្នកចង់សរសេរ
- ពេលសរសេរអក្សរចប់រួចរាល់លោកអ្នកអាចធ្វើការ ប្តូរម៉ូតអក្សរ ប្តូរទំហំអក្សរ និងប្តូរពណ៌អក្សរ បានតាមចិត្ត។

## រូបភាពទទួលបានក្រោយការ ឌីសាញ រួច



# មជ្ឈមណ្ឌលកុំព្យូទ័រ និងជំនាញបច្ចេកវិទ្យា សុវណ្ណភក្ត្រ

# លំហាត់អនុវត្តទី១៧ ការដាក់រូបភាពធ្វើពាណិជ្ជកម្មលើឡានធំ

- ➢ ដំបូងទាញរូបភាពឡានចូល រួចទាញរូបភាពពាណិជ្ជកម្មដែលបានឌីសាញរួចចូលមកដែល
- ➢ ចុច Ctrl + A លើរូបភាពពាណិជ្ជកម្ម ហើយចុច Ctrl + C
- ➢ បន្ទាប់មកទៀត ចូលមក Tab រូបភាព ឡាន
- ❖ ចុចបង្កើត Layer ថ្មីមួយ ហើយចុច Tab Fiter រួចចុចយកពាក្យ Vanishing Point……
- ❖ បន្ទាប់មកទៀត ប្រើ Create Plane Tool (C) គូសកន្លែងដែលចង់ដាក់ពាណិជ្ជកម្ម




- ➢ ចុច Ctrl + V នោះវានិងចេញរូបពាណិជ្ជកម្មដែលយើងបានចុច Ctrl + C លើមុន
- ➢ ចុច Ctrl + T ហើយទាញវាមកដាក់កន្លែងដែលយើងបានគូស ចុច Ctrl ឱ្យជាប់ ដើម្បីសារ៉េឱ្យត្រូវ
- ➢ រួចចុច ok



## រូបភាពទទួលបានក្រោយការ ឌីសាញ រូប




# មជ្ឈមណ្ឌលកុំព្យូទ័រ និងជំនាញបច្ចេកវិទ្យា សុវណ្ណរក្ស

# លំហាត់អនុវត្តន៍ទី១៨ របៀបលុបផ្ទៃខាងក្រោយនៃរូបភាព យកជា File PNG ទុកប្រើ

- ដំបូងទាញរូបភាពដើមចូល
- ចុច Tab Select នៅផ្នែកខាងលើ រួចចុច យកពាក្យ Subject
- សូមចុចប្រើ Tools Magic Wand ដើម្បីយកមកចុចនៅកន្លែងណាដែលមិនទាន់បាន Select ចំនៅពេលប្រើ ត្រូវចុច Alt ឱ្យជាប់ ចាំចុច



ចុច Tab Select នៅផ្នែកខាងលើដដែល រួចចុចយកពាក្យ  Select and Mask...( Alt + Ctrl + R )




ត្រូវកន្លែង Decontaminate  Colors ត្រូវចុច ធីក

បន្ទាប់មក ចុច OK

ពេល Save សូម Save យកជា File PNG



# វិធីអនុវត្តទី២

- ដំបូងទាញរូបភាពដើមចូល
- ចុច Tab Window នៅផ្នែកខាងលើ រួចចុច យកពាក្យ Channels




- ចុច លើពាក្យ Blue រួចទាញវា យកមកបង្កើត Layer ថ្មី




- ហើយចុច Ctrl + L



- បន្ទាប់មក ចុច សារ៉េ ឱ្យចេញពណ៌ សរ ដាច់ និងពណ៌ ខ្មៅ ដាច់ រួចចុច OK




- បន្ទាប់មកទៀត យើងត្រូវចុច បើកភ្នែក Layer វិញទាំងអស់ នៅកន្លែង Channels និង
- ចុច Ctrl ឱ្យជាប់ ហើយយក ម៉ៅ មកចុច ពីលើ Layer Blue Copy
- ហើយចូលទៅ Tab Select យកពាក្យ Inverse




- បន្ទាប់មក ត្រឡប់មក ចុច កន្លែង Tab Layer យើងវិញ រួចចុច Add Mask



## រូបភាពទទួលបានក្រោយការ ឌីសាញ រួច មិន មានផ្ទៃខាងក្រោយ ជា File PNG



# មជ្ឈមណ្ឌលកុំព្យូទ័រ និងជំនាញបច្ចេកវិទ្យា សុវណ្ណរក្ស

## លំហាត់អនុវត្តន៍ទី១៩ របៀប Select Layer, តំរៀប Layer និង Transform Layer

### របៀប Select Layer

- Alt + [ : សម្រាប់រំកិល Select ទៅកាន់ Layer ខាងក្រោមម្តងមួយៗ
- Alt + ] : សម្រាប់រំកិល Select ទៅកាន់ Layer ខាងលើម្តងមួយៗ

### របៀបតំរៀប Layer

- Ctrl + [ : សម្រាប់រំកិល Layer ទៅខាងក្រោមម្តងមួយទីតាំង
- Ctrl + ] : សម្រាប់រំកិល Layer ទៅខាងលើម្តងមួយទីតាំង
- Shift + Ctrl + [ : សម្រាប់រំកិល Layer ទៅកាន់ទីតាំងខាងក្រោមបំផុត
- Shift + Ctrl + ] : សម្រាប់រំកិល Layer ទៅកាន់ទីតាំងខាងលើបំផុត

### របៀប Transform Layer

Transform ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការ ពង្រីកបង្រួម បង្វិល ឬត្រឡប់ Layer។

ចុច Edit Menu=> Free Transform( Ctrl + T )




### មានជម្រើសច្រើន:

- Free transform : សម្រាប់ពង្រីកបង្រួម ឬបង្វិល Layer
- Scale : សម្រាប់ពង្រីកបង្រួម Layer

- Rotate : សម្រាប់បង្វិល Layer
- Skew : សម្រាប់ប្តូរទ្រង់ទ្រាយ Layer ជារាងប្រលេឡូក្រាម
- Distort : សម្រាប់ប្តូរទ្រង់ទ្រាយរបស់ Layer ទៅតាមជ្រុងដែលបានទាញ
- Perspective : សម្រាប់ផ្លាស់ប្តូរទ្រង់ទ្រាយរបស់ Layer ទៅតាមផ្នែកដែល
- Warp : សម្រាប់ផ្លាស់ប្តូរទ្រង់ទ្រាយរបស់ Layer ទៅតាមការទាញរបស់ Mouse pointer
- Rotate $180^0$ : សម្រាប់ត្រឡប់ Layer ទៅស្តាំ $180^0$
- Rotate $90^0$ CW : សម្រាប់ត្រឡប់ Layer ទៅស្តាំ $90^0$
- Rotate $90^0$ CCW : សម្រាប់ត្រឡប់ Layer ទៅឆ្វេង $90^0$
- Flip Horizontal : សម្រាប់ត្រឡប់ Layer បញ្ច្រាស់ពីឆ្វេងទៅស្តាំ ឬពីស្តាំទៅឆ្វេង
- Flip Vertical : សម្រាប់ត្រឡប់ Layer បញ្ច្រាស់ពីលើទៅក្រោម ឬពីក្រោមទៅលើ



## លំហាត់អនុវត្តទី២០ របៀបកែប្រែពន្លឺជាមួយ Adjustment

- ទាញរូបភាព ចូល រូបភាពណាដែលលោកអ្នកចង់ធ្វើការប្រើប្រាស់ Brightness/Contrast: ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកែប្រែពន្លឺនិងភាពច្បាស់ទៅឱ្យរូបភាព។
- ចុច Image => Adjustments => Brightness/Contrast
- Brightness ទាញ Handle កែប្រែពន្លឺ
- Contrast ទាញ Handle កែប្រែភាពច្បាស់របស់វា រួចចុច Ok




## ការប្រើប្រាស់ Level

- ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកែប្រែកម្រិតពន្លឺទៅឱ្យរូបភាព។
- ចុច Image => Adjustments => Levels( Ctrl + L )
- Channel: ជ្រើសរើសលក្ខណៈដែលត្រូវកែតម្រូវ Channel
- Input Levels: កន្លែងសម្រាប់កែតម្រូវ Shadows, Midtones and Hight Light ឱ្យរូបភាព
- Output Levels: កន្លែងកែប្រែកម្រិត Pixels

## បើករូបភាព ដោយធ្វើការកែប្រែពន្លឺ




## ការប្រើប្រាស់ Curves

ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកែប្រែកម្រិតពន្លឺទៅឲ្យរូបភាព។

❶ ចុច Image => Adjustments => Curves( Ctrl + M )



## ការប្រើប្រាស់ Vibrance

ប្រើប្រាស់សម្រាប់ធ្វើការកែប្រែកម្រិតពណ៌របស់រូបភាពឱ្យទៅជាលក្ខណៈ ស្លេក ឬច្បាស់ជាងមុន។

- ចុច Image => Adjustments => Vibrance
- Vibrance ទាញ Handle កែប្រែពណ៌
- Saturation ទាញ Handle កែប្រែពណ៌
- ចុច Ok




## ការប្រើប្រាស់ Hue/Saturation

ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកែប្រែពណ៌របស់រូបភាពឲ្យទៅជាពណ៌ណាមួយផ្សេងទៀត។

- ចុច Image => Adjustments => Hue/Saturation( Ctrl + U )



- Saturation ទាញ Handle កែប្រែពណ៌
- Hue ទាញ Handle កែប្រែពណ៌
- Lightness ទាញ Handle កែប្រែ ពន្លឺ រួចចុច Ok




## ការប្រើប្រាស់ Color Balance

ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកែប្រែពណ៌របស់រូបភាពឱ្យទៅជាពណ៌ណាមួយផ្សេងទៀត។

- ចុច Image => Adjustments => Color Balance( Ctrl + B )
- ចុចទាញ Handle កែប្រែពណ៌
- ចុច Ok



## ការប្រើប្រាស់ Black and White

ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកែប្រែពណ៌របស់រូបភាពឱ្យទៅជាពណ៌សខ្មៅ។

❶ ចុច Image => Adjustments => Black & White( Alt + Shift + Ctrl + B )

❷ ចុចទាញ Handle កែប្រែពណ៌

❸ ចុច Ok



## ការប្រើប្រាស់ Photo Filter

ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកែប្រែពណ៌រូបភាពឱ្យទៅជាពណ៌ណាមួយផ្សេងទៀត។

❶ ចុច Image => Adjustments => Photo Filter

❷ ជ្រើសរើស Color => Density ទាញ Handle

❸ ចុច Ok







## ការប្រើប្រាស់ Invert

ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការកែប្រែរូបភាពធម្មតាឱ្យទៅរូបភាពដែលមានលក្ខណៈស្លេកនិងងងឹត។

❶ ចុច Image => Adjustments => Invert( Ctrl + I )


File Edit Image Layer Type Select Filter 3D View Plugins Window Help
Transform Controls
landsca
Mode
Adjustments
Auto Tone Shift+Ctrl+L
Auto Contrast Alt+Shift+Ctrl+L
Auto Color Shift+Ctrl+B
Image Size... Alt+Ctrl+I
Canvas Size... Alt+Ctrl+C
Image Rotation
Crop
Trim...
Reveal All
Duplicate...
Apply Image...
Calculations...
Brightness/Contrast...
Levels... Ctrl+L
Curves... Ctrl+M
Exposure...
Vibrance...
Hue/Saturation... Ctrl+U
Color Balance... Ctrl+B
Black & White... Alt+Shift+Ctrl+B
Photo Filter...
Channel Mixer...
Color Lookup...
Invert Ctrl+I
Posterize...
Threshold...



## លំហាត់អនុវត្តទី២១ របៀបកាត់ ក អាវ ជាមួយមនុស្ស

- ត្រូវបង្កើតក្រដាសកិច្ចការមួយ យកទំហំ 4.67cm X 6cm ( Resolution យក 300 - 500 )
- ទាញរូបថត ដែលត្រូវកាត់ ចូល ទាញដាក់ចូលក្នុង ក្រដាសកិច្ចការដែលយើងបានបង្កើតមុននិង




- បញ្ជាក់ បើរូបថតយើងជាង File Index
- យើងត្រូវ ប្តូរ វាជា File PNG វិញសិន
- ដំបូង ចុច Tab Image ➔ Mode ➔ RGB Color




- ត្រូវធ្វើរូបឱ្យទៅជា File PNG សិន ចាំទាញចូល



- ចុច Ctrl + T ដើម្បី សារ៉េ អាវធំ ឱ្យស៊ីគ្នា ជាមួយរូប
- ដើម្បីងាយស្រួលក្នុងការ សារ៉េ យើងត្រូវ ចុច Ctrl + + និង Ctrl + - ដើម្បីពង្រីក បង្រួម វា
- បន្ទាប់មកទៀត ត្រង់ ក អាវ និង ក របស់ រូប



- ត្រូវឈរលើ Layer អាវធំ ប្រើ Tool Rectangular Marquee
- យកវាមកគូស នៅត្រង់ ចំណុច ក អាវ និង រួចចុច Ctrl + T ហើយ ចុច ម៉ៅស្តាំ យកពាក្យថា Warp




- រួចធ្វើការ សារ៉ រូប ក អាវ ឱ្យស៊ីជាមួយនិង ក
- សារ៉ ស្អាត លោកអ្នកគិតថា សមរម្យ ហើយ រួច Ctrl + D ដើម្បី ដោះ Select ចេញវិញ



## លំហាត់អនុវត្តន៍ទី២២ របៀបបង្កើត Mockup

- ទាញរូប Background ចូល សម្រាប់ប្រើ
- ទាញរូប iPhone សម្រាប់ ធ្វើជា Mockup




- បន្ទាប់មកទៀត ទាញរូប iPhone ចូលទៅក្នុង Background រួច សារ៉េ ដែលលោកអ្នកចង់បាន




បន្ទាប់មកទៀត យើងទាញរូបដែលត្រូវដាក់បញ្ចូលក្នុង iPhone សម្រាប់ ធ្វើជា Mockup ចូលទៅក្នុង Layer Background ដូចរូប iPhone ដែរ

➢ បើវាធំ ចុច Ctrl + T បង្រួមវាឱ្យមកតូចល្មមដែលលោកអ្នកគិតថាសមរម្យ




បន្ទាប់មក សូមប្រើ Tools Rectangle មកគូសពីលើរូបដែលយើងទាញចូល ឱ្យប៉ុនរូប រួចចុច បិទភ្នែក Layer រូបសិន




❖ រួចចុច Right-Click (ម៉ៅស្ដាំ) លើ Layer Tools Rectangle ដែលយើងបានគូស

❖ ចុចយកពាក្យ Convert to Smart Object

❖ ឈរនៅលើ Layer ដែលយើងបាន Convert to Smart Object និងដដែល

❖ ទំលាក់កម្រិតច្បាស់វាឱ្យមកសល់ត្រឹម 40% សិន ដើម្បីទាញវាឱ្យស៊ីនិងរូប iPhone

❖ ចុច Ctrl + T រួចចុច Right-Click ( ម៉ៅស្តាំ ) យកពាក្យ Distort




❖ បើលោកអ្នក ចុច សារ៉េ មិនទាន់ស្អាតតែមមិនស៊ីគ្នា សូមរួចចុច Right-Click ( ម៉ៅស្តាំ ) យកពាក្យ Warp ម្តង ដើម្បីសារ៉េ ឱ្យតែម iPhone ស៊ីគ្នាជាមួយ Tools Rectangle 1 ដែលយើងបានគូស ពណ៌ប៉ៃតង និង

❖ ក្រោយពីលោកអ្នក សារ៉េ ឱ្យតែម iPhone ស៊ីគ្នាជាមួយ Tools Rectangle 1 ដែលយើងបានគូស ពណ៌ប៉ៃតង និងហើយ គិតថាស្អាតសមរម្យហើយ

❖ សូមចុច ENTER

## ខាងក្រោមនេះជារូបដែលយើងសារ៉េរួច









- ឈរនៅលើ Rectangle 1 ដដែល ចុច Double Click ( ចុច ២ដងឱ្យញាប់ ) នៅលើវា
- វានិងលោតផ្ទាំង Rectangle 1 ដែលយើងបានគូស ពណ៌បៃតង
- សូមទាញ រូបដែលត្រូវដាក់បញ្ចូលក្នុង iPhone សម្រាប់ ធ្វើជា Mockup ចូលម្តងទៀត
- រួច ចុច Ctrl + T សារេ វាឱ្យស្អាត
- រួច ចុច ខ្វែង វា
- នៅពេលវាលោត ផ្ទាំង មក
- សូម យក Yes



# រូបដែលយើងទទួលបានក្រោយ ឌីសាញ




សូមធ្វើការ ស្កេន **RQ Code** ខាងក្រោមនេះជា ក្រុម សម្រាប់ឱ្យចូលទៅដោនឡូត រូបភាព **Files** ផ្សេងៗរាប់រយ **Free** សម្រាប់យកមករៀន ឌីសាញ

@SOVANREAK4G
RAPHICDESIGN

# ប្លង់ក្តារចុចយូនីកូដ




## ដៃឆ្វេង ដៃស្តាំ

